# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


និយ័តករគណនេយ្យនិងសវនកម្ម
ACCOUNTING AND AUDITING REGULATOR

លេខ...........................ន. គ. ស .......


ថ្ងៃអង្គារ ៩កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦

## សេចក្តីជូនដំណឹងសាឡើងវិញ
## ស្តីពី
## ការជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាលជំនាញ "ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង"

**និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)** គឺជាស្ថាប័នតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ន.គ.ស. បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជារយៈពេល១០ឆ្នាំ (២០២៥-២០៣៥) និងផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មរយៈពេល១០ឆ្នាំ (២០២១ -២០៣០) ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងប្រកបដោយការទទួលខុសត្រូវខ្ពស់។ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់ការអភិវឌ្ឍន៍ និងការកសាងសមត្ថភាពមន្ត្រី ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងផែនការអភិវឌ្ឍន៍ស្ថាប័ន ន.គ.ស. ត្រូវការជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាលដើម្បីផ្តល់សេវាបណ្តុះបណ្តាលជំនាញ "**ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង**"។

ក្នុងន័យនេះ ន.គ.ស. សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ដែលមានគុណវុឌ្ឍិដូចខាងក្រោម៖

### ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែ៖

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មពេញលេញ
- មានបទពិសោធន៍លើការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងមានរយៈពេលយ៉ាងតិច៥ឆ្នាំ
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជាត្រូវបានលើកទឹកចិត្ត។

### ២. លក្ខខណ្ឌយោងការងារ

- បណ្តុះបណ្តាលមន្ត្រី ន.គ.ស. ឱ្យមានការយល់ដឹងស៊ីជម្រៅលើភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- រៀបចំផែនការក្នុងការបង្រៀនទាក់ទងទៅនឹងជំនាញភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង ដែល ន.គ.ស. បានតម្រូវ
- រៀបចំការវាយតម្លៃ និងមតិកែលម្អ។

### ៣. កម្រៃ

កម្រៃសម្រាប់ការបណ្តុះបណ្តាល "ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង" គឺបើកចំហរសម្រាប់ការចរចា។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111
អ៊ីមែល : info@acar.gov.kh

## ៤. រយៈពេលនៃការបណ្ដុះបណ្ដាល

ការបណ្ដុះបណ្ដាល "ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង" មានរយៈពេលចន្លោះពី ៣-៥ថ្ងៃ។ កិច្ចសន្យានៃការផ្ដល់សេវាមួយនេះ នឹងត្រូវបង្កើតឡើងរវាង ន.គ.ស. ជាមួយនឹងក្រុមហ៊ុន ឬគ្រឹះស្ថានបណ្ដុះបណ្ដាលដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

## ៥. ការដាក់ពាក្យ

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្ដុះបណ្ដាលដែលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្ដីចំណាប់អារម្មណ៍មក ន.គ.ស តាមរយៈអ៊ីម៉ែលgeneral_affairs_dept@acar.gov.kh និង accounting@acar.gov.kh ត្រឹមថ្ងៃទី៦ ខែកុម្ភៈឆ្នាំ២០២៦ ដោយដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ៖ ០៦៩ ៧៨៣ ៩៣៦ / ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**